# I. ខុទ្ទកាល័យព្រះមហាក្សត្រ

## ១. ព្រះរាជក្រម

ព្រះរាជក្រម លេខ នស/រកម/០១៩៤/០១ក

យើង

ព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័ន

នាថបរិវេណ ឧត្តមគតិសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជា បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ១វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងទី ២ ចុះថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៩៤

## ប្រកាសឲ្យប្រើ

ប្រកាសឱ្យប្រើ ច្បាប់ ដែលបានអនុម័តដោយរដ្ឋសភានៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការ ផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀង អំពីឥណទានអភិវឌ្ឍន៍ សំរាប់ឆ្នាំ ១៩៩៤ ដែលបាន ស្រុះស្រួលគ្នា នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ រវាងព្រះរាជាណាចក្រកម្ពុជា និង សមាគមអន្តរជាតិអភិវឌ្ឍន៍ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ÷

# ច្បាប់

## ស្ដីពីការផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងអំពីឥណទាន

## អភិវឌ្ឍន៍សំរាប់ ឆ្នាំ ១៩៩៤ ដែលបានស្រុះស្រួលគ្នានៅ

## ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៣

## រវាង

## ព្រះរាជាណាចក្រកម្ពុជា និង សមាគមអន្តរជាតិអភិវឌ្ឍន៍

**មាត្រា ១ :** ត្រូវបានអោយសច្ចាប័នទៅលើកិច្ចព្រមព្រៀង អំពីឥណទានអភិវឌ្ឍន៍សំរាប់ឆ្នាំ ១៩៩៤ ដែលសមាគមអន្តរជាតិអភិវឌ្ឍន៍ បានស្រុះស្រួលឱ្យព្រះរាជាណាចក្រកម្ពុជា ខ្ចីប្រាក់ចំនួន សែសិបប្រាំលានពីរសែន ( ៤៥.២០០.០០០ ) សិទ្ធិដកប្រាក់ ពិសេស ( ៤៥.២០០.០០០ S.D.R Special Drawing Rights ) ដើម្បី ពង្រឹង សកម្មភាព សេដ្ឋកិច្ច ចំបងនិងនិតិសម្បទា នៃហេដ្ឋារចនាសម្ព័ន្ធ សាធារណៈជាអាទិ៍ ខាងវិស័យកសិកម្ម អប់រំ សុខាភិបាល អគ្គិសនី និងដឹកជញ្ជូន ។

**មាត្រា ២ :** ត្រូវបានប្រកាសឱ្យប្រើជាប្រញាប់ នូវច្បាប់នេះ ។

ព្រះហស្តលេខា

ធ្វើនៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៤

**នរោត្តម សីហនុ**

បានដាក់ថ្វាយទត

និងសូមព្រះរាជហស្តលេខាដោយ

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**

ឆ្លងព្រះរាជបញ្ជាដើម្បីអនុវត្ត

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហត្ថលេខា ហត្ថលេខា

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**